**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៖** ២៦៥ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យធ្វើនិយ័តកម្មឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមៈ

ក-និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែកមានមុខសញ្ញា)

ឯកតាៈ លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | **និយ័តកម្មចេញ** | | | | 1 645 994 | |
| | ៩៩- ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | | | | 1 645 994 | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | 342 294 | 342 294 | - | 342 294 | 0 |
| ៦៥ | ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | 638 186 | 638 186 | - | 638 186 | 0 |
| ៥០ | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 665 514 | 665 514 | - | 665 514 | 0 |
| | **និយ័តកម្មចូល** | | | 1 645 994 | | |
| | ១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | 1 645 994 | | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | 0 | 0 | 342 294 | - | 342 294 |
| ៦៥ | ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | 36 185 | 36 185 | 638 186 | - | 674 371 |
| ៥០ | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 0 | 0 | 665 514 | - | 665 514 |

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ